នាយកដ្ឋានបុគ្គលិក
លេខ ...
ចុះថ្ងៃទី២១ ខែ០៦ ឆ្នាំ២០២១
ម៉ោង ០៣ ០៤
បញ្ជូនទៅ ...

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
នាយកដ្ឋានរដ្ឋបាលទូទៅ
ចូល
លេខ ...
ថ្ងៃទី២១ ខែ០៦ ឆ្នាំ២១

# ព្រះរាជក្រឹត្យ

នស/រកត/០៦២១/៨៤៩

## ស្តីពី

## ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ :**

ត្រូវបានបង្កើត គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ សរសេរជាអក្សរកាត់ថា "គ.ក.រ" ដើម្បីដឹកនាំ និងសម្របសម្រួលការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *



Scanned with CamScanner

## ជំពូកទី២

## មុខងាររបស់ គ.ក.រ

**មាត្រា២** :

គ.ក.រ បំពេញមុខងារសំខាន់ៗដូចខាងក្រោម៖

- ដឹកនាំ គាំទ្រ និងសម្របសម្រួលការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំ និងអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈផ្អែកលើគោលនយោបាយរបស់រាជរដ្ឋាភិបាល
- គាំទ្រដល់ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងកម្មវិធីកែទម្រង់ដទៃទៀតរបស់រាជរដ្ឋាភិបាល
- លើកសំណើជូនរាជរដ្ឋាភិបាលអនុម័តលើគោលនយោបាយ កម្មវិធី យុទ្ធសាស្ត្រ និងផែនការសកម្មភាពបម្រើឱ្យការកែទម្រង់រដ្ឋបាលសាធារណៈ
- លើកសំណើជូនរាជរដ្ឋាភិបាល ក្នុងការរៀបចំក្របខណ្ឌគតិយុត្ត សម្រាប់ការគាំទ្រដល់ការកែទម្រង់រដ្ឋបាលសាធារណៈ
- សម្របសម្រួល និងផ្តល់ជំនួយបច្ចេកទេសដល់ក្រសួង ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការចូលរួមអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ
- ពិនិត្យ និងអនុម័តសូចនាករសមិទ្ធកម្មគន្លឹះ និងដឹកនាំការងារត្រួតពិនិត្យ ការតាមដាន និងការវាយតម្លៃការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ
- ធ្វើរបាយការណ៍អំពីវឌ្ឍនភាពនៃការងារកែទម្រង់រដ្ឋបាលសាធារណៈជូនរាជរដ្ឋាភិបាល និងជំរុញការផ្សព្វផ្សាយសមិទ្ធផលនៃការងារកែទម្រង់រដ្ឋបាលសាធារណៈ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ដើម្បីជំរុញការងារកែទម្រង់រដ្ឋបាលសាធារណៈ
- បំពេញការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចពីរាជរដ្ឋាភិបាល។

## ជំពូកទី៣

## សមាសភាព និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ គ.ក.រ

**មាត្រា៣** :

គ.ក.រ. មានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| ១. រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ | ប្រធាន |
| ២. រដ្ឋលេខាធិការប្រចាំការក្រសួងមុខងារសាធារណៈ | អនុប្រធានប្រចាំការ |
| ៣. រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | អនុប្រធាន |
| ៤. រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាតំណាងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ១រូប | អនុប្រធាន |
| ៥. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាតំណាងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ១រូប | អនុប្រធាន |
| ៦. រដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាតំណាងគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ១រូប | អនុប្រធាន |
| ៧. រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ១រូប | សមាជិក |



Scanned with CamScanner

៨. រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប សមាជិក
៩. រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ១រូប សមាជិក
១០. រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ១រូប សមាជិក
១១. រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១រូប សមាជិក
១២. រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល ១រូប សមាជិក
១៣. រដ្ឋលេខាធិការក្រសួងផែនការ ១រូប សមាជិក
១៤. រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១រូប សមាជិក
១៥. រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១រូប សមាជិក
១៦. រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១រូប សមាជិក
១៧. រដ្ឋលេខាធិការក្រសួងបរិស្ថាន ១រូប សមាជិក
១៨. រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម ១រូប សមាជិក
១៩. រដ្ឋលេខាធិការក្រសួងព័ត៌មាន ១រូប សមាជិក
២០. រដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ១រូប សមាជិក
២១. រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ១រូប សមាជិក
២២. រដ្ឋលេខាធិការក្រសួងសុខាភិបាល ១រូប សមាជិក
២៣. រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន ១រូប សមាជិក
២៤. រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ១រូប សមាជិក
២៥. រដ្ឋលេខាធិការក្រសួងទេសចរណ៍ ១រូប សមាជិក
២៦. រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ១រូប សមាជិក
២៧. រដ្ឋលេខាធិការក្រសួងកិច្ចការនារី ១រូប សមាជិក
២៨. រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប សមាជិក
២៩. រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ១រូប សមាជិក
៣០. រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការនៃក្រសួងមុខងារសាធារណៈ សមាជិក
៣១. ប្រធានលេខាធិការដ្ឋាន គ.ក.រ. សមាជិកអចិន្ត្រៃយ៍

ក្រៅពីសមាជិកខាងលើនេះ គ.ក.រ. អាចស្នើបន្ថែមសមាជិកជាតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធតាមការចាំបាច់។

ប្រធាន គ.ក.រ. ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

អនុប្រធាន និងសមាជិក គ.ក.រ. ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់ប្រធាន គ.ក.រ.។

## ជំពូកទី៤
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់ គ.ក.រ

**មាត្រា៤** :

គ.ក.រ. ត្រូវប្រជុំរៀងរាល់ត្រីមាស។ កិច្ចប្រជុំនេះ ដឹកនាំដោយប្រធាន ឬអនុប្រធានប្រចាំការតាមការចាំបាច់។

ក្នុងករណីចាំបាច់ ប្រធាន គ.ក.រ. អាចមានសិទ្ធិអញ្ជើញប្រធានស្ថាប័ន ឬតំណាងរបស់ប្រធានស្ថាប័ន ឬអាជ្ញាធរ ព្រមទាំងមន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ចូលរួមប្រជុំ និងបំពេញការងារផ្សេងៗតាមបទបញ្ញត្តិ ដែលមានក្នុងព្រះរាជក្រឹត្យនេះ។

គ.ក.រ. មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន តំណាងសង្គមស៊ីវិល ទីប្រឹក្សា ឬអ្នកជំនាញការជាតិ និងអន្តរជាតិ ចូលរួមប្រជុំ ក្នុងឋានៈជាសមាជិកសង្កេតការណ៍ ឬជាអ្នកផ្តល់យោបល់តាមការចាំបាច់។

គ.ក.រ. ត្រូវធ្វើរបាយការណ៍ប្រចាំឆមាសជូនប្រមុខរាជរដ្ឋាភិបាល។

គ.ក.រ. មានសិទ្ធិប្រើរូបសញ្ញា និងត្រារបស់ក្រសួងមុខងារសាធារណៈ ដើម្បីដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួន។

**មាត្រា៥ :**

គ.ក.រ. មានអនុគណៈកម្មាធិការនានា ដើម្បីគាំទ្រដល់ការបំពេញមុខងារដូចមានចែងក្នុងមាត្រា២ខាងលើ។

គ.ក.រ. មានលេខាធិការដ្ឋានជាសេនាធិការសម្រាប់គាំទ្រកិច្ចដំណើរការ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន និងអនុគណៈកម្មាធិការ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦ :**

ក្រសួង ស្ថាប័នថ្នាក់ជាតិ ត្រូវរៀបចំបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួង ស្ថាប័ន ដែលដឹកនាំដោយថ្នាក់ដឹកនាំជា អនុប្រធាន ឬសមាជិកគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ។

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួង ស្ថាប័ន ត្រូវបង្កើតឡើងដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី។

**មាត្រា៧ :**

រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ ដែលដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរាជធានី ខេត្ត ត្រូវបង្កើតឡើងដោយដីការបស់អភិបាលនៃគណៈអភិបាលសាមី។

## ជំពូកទី៥
## ធនធាន និងថវិការបស់ គ.ក.រ

**មាត្រា៨ :**

ធនធាន និងថវិកាសម្រាប់ទ្រទ្រង់ដំណើរការនៃការងាររបស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ មានប្រភពពីថវិកាជាតិ ដែលជាកញ្ចប់ថវិកាដោយឡែកក្នុងថវិកាក្រសួងមុខងារសាធារណៈ។

ធនធានផ្សេងទៀត រួមមាន ថវិកា និងធនធានគាំទ្រផ្នែកសម្ភារៈ និងបច្ចេកទេសពីក្រសួង ស្ថាប័នដទៃរបស់រាជរដ្ឋាភិបាល កម្មវិធីកែទម្រង់ផ្សេងទៀត និង/ឬ ធនធាន និងថវិកាគាំទ្រផ្នែកសម្ភារៈ និងបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ និងពីប្រភពស្របច្បាប់ដទៃទៀត។

ការគ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិ និងហិរញ្ញវត្ថុរបស់ គ.ក.រ. ត្រូវអនុវត្តតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាធរមាន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *



Scanned with CamScanner

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា៩ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០..**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ *ចន្ទ ១៤រោច* ខែ *ជេស្ឋ* ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី *០៧* ខែ *មិថុនា* ឆ្នាំ២០២១

*នរោត្តម សីហមុនី*

*នស.២១០៦.៤៥៣*

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសល្យបណ្ឌិត **ប៊ិន ឈិន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ព្រុំ សុខា**



Scanned with CamScanner